ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

ខេត្តស្វាយរៀង

ស្រុករំដួល

ឃុំកំពង់អំពិល

លេខ:..០០៨១.......

# ដីកា

# ស្តីពី

# ការបង្ការ និងទប់ស្កាត់គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ឆ្នាំ២០០១
- បានឃើញអនុក្រិត្យលេខ២២ អនក/បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការ អំណាច តួនាទី និងភារកិច្ច ឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចរបស់អង្គប្រជុំក្រុមប្រឹក្សាឃុំកំពង់អំពិលស្តីពីវិធានការបង្ការ និងទប់ស្កាត់ គ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងស្រវឹង ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៥
- យោងលទ្ធផលសិក្ខាសាលាស្តីពី "ការបង្ការនិងកាត់បន្ថយផលប៉ះពាល់នៃគ្រឿងស្រវឹងគ្រឿងស្រវឹងនៅក្នុងសហគមន៍" នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥។

ដោយមើលឃើញថាបញ្ហាដែលបង្កឡើងដោយអ្នកប្រើប្រាស់គ្រឿងស្រវឹងបានធ្វើឲ្យមានអំពើហិង្សា ភាពឥត សណ្តាប់ធ្នាប់ អសន្តិសុខ ភាពក្រីក្រ និងប៉ះពាល់ដល់សុខភាពជារួមរបស់ប្រជាពលរដ្ឋក្នុងឃុំកំពង់អំពិល

ដូច្នេះ ក្រុមប្រឹក្សាឃុំកពង់អំពិល

## សម្រេច

ប្រការ១ ៖ ត្រូវកោះហៅអ្នកពិសារគ្រឿងស្រវឹងបង្កបញ្ហាមកអប់រំ លើកទី១ លើកទី២ ហើយលើកទី៣ នៅមិនរាងចាលនឹងត្រូវផាកពិន័យជាប្រាក់ពី១០០០០៛(មួយម៉ឺនរៀល) ទៅ៥០០០០៛(ប្រាំម៉ឺនរៀល)។

ប្រការ២៖ ហាមប្រើឲ្យទិញ ឬលក់គ្រឿងស្រវឹងឲ្យក្មេងចាប់ពីអាយុ១៥ឆ្នាំចុះក្រោម។ បើជនណាប្រព្រឹត្តិផ្ទុយនឹងប្រការនេះ ត្រូវផាកពិន័យជាប្រាក់ពី១០០០០៛ (មួយម៉ឺនរៀល) ទៅ ៥០០០០៛ (ប្រាំម៉ឺនរៀល)។

ប្រការ៣៖ មិនអនុញ្ញាតអោយមានការលក់ផលិតផលគ្រឿងស្រវឹង ឬប្រើប្រាស់គ្រឿងស្រវឹងគ្រប់

ប្រភេទនៅ តាមបរិវេណវត្តអារាម សាលារៀន មណ្ឌលសុខភាព និងពិធីបុណ្យនានា ។ បើជនណា ប្រព្រឹត្តផ្ទុយនឹងប្រការនេះ នឹងត្រូវផាកពិន័យជាប្រាក់ពី ៥០,០០០ រៀល (ប្រាំម៉ឺនរៀល) ទៅ ១៥០,០០០ រៀល (មួយសែនប្រាំម៉ឺនរៀល) ។

**ប្រការ៤:** អ្នកកល់គ្រឿនស្រវឹង មិនត្រូវលក់ឱ្យអ្នកទិញដែលស្ថិតក្នុងស្ថានភាពស្រវឹង ។ បើជនណាប្រព្រឹត្តផ្ទុយនឹងប្រការនេះ នឹងត្រូវទទួលផាកពិន័យជាប្រាក់ពី ២០,០០០ រៀល (ពីរម៉ឺនរៀល) ទៅ ៥០,០០០ រៀល (ប្រាំម៉ឺនរៀល) ។

**ប្រការ៥:** ជនណាប្រព្រឹត្តសកម្មភាពដូចខាងក្រោម:

- ដើរឡូឡា ស្រែករំខានអ្នកដទៃ
- បើកបរទោចក្រយាន ឬ យានយន្តគ្រប់ប្រភេទ ដោយបន្លឺសម្លេងខ្លាំងៗ ចាប់ពីរម៉ោង ១០ យប់តទៅ
- បើកសម្លេងធុងបាស់កំសាន្ត ឬ គ្រឿងបំពងសម្លេងចាប់ពីម៉ោង ១០ យប់តទៅ ។

ដែលស្ថិតនៅក្រោមឥទ្ធិពលគ្រឿងស្រវឹង បណ្តាលឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់ និង សិទ្ធិអ្នកដទៃ ត្រូវផាកពិន័យជាប្រាក់ ២០០,០០០ រៀល (ពីរសែនរៀល) ទៅ ៥០០,០០០ រៀល (ប្រាំសែនរៀល) ។

**ប្រការ៦:** ក្នុងករណីដែលបណ្តាលឱ្យមានអំពើហិង្សាកើតឡើង ដោយសារស្ថិតក្រោមឥទ្ធិពលគ្រឿងស្រវឹងនៅក្នុងគ្រួសារ ឬ ប្រព្រឹត្តចំពោះជនណាម្នាក់ ជនល្មើសនឹងត្រូវចាត់ការ ទៅច្បាប់ស្តីពីការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ ។

**ប្រការ៧:** អាជ្ញាធរមូលដ្ឋាន ដែលមានមេភូមិ សមាជិកក្រុមប្រឹក្សាឃុំ ប៉ូលីសប៉ុស្តិ៍រដ្ឋបាល គ្រូបង្រៀន បុគ្គលិកសុខាភិបាល យុវជន និង ព្រះសង្ឃត្រូវផ្សព្វផ្សាយដល់ប្រជាជន ក្នុងសហគមន៍ឱ្យបានជ្រួតជ្រាប ។

**ប្រការ៨:** ដីការនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

ធ្វើនៅកំពង់អំពិល ថ្ងៃទី ២៦ ខែមិថុនា ឆ្នាំ២០១៥

**មេឃុំកំពង់អំពិល**

រាជ. សះផុន

**<u>ចម្លងជូន</u>**

- សាលាខេត្តស្វាយរៀង
- សាលាស្រុករំដួល
  (ដើម្បីជូនជ្រាប)
- ដូចមានចែងក្នុងប្រការ១
  (ដើម្បីអនុវត្ត)
- ឯកសារកាលប្បវត្ត